**for a living planet®**

**WWF-Cambodia**

21, Street 322,
BoeungKeng Kang I,
Phnom Penh, Cambodia
P.O. Box: 2467

Tel: +855 23 218 034
Fax: +855 23 211 909

www.wwf.org.kh
www.panda.org/greatermekong
wwfcambodia@wwf.org.kh

| សេចក្តីប្រកាសព័ត៌មាន | សម្រាប់ចេញផ្សាយបន្ទាន់ |
|---|---|

# សហគមន៍ពឹងអាស្រ័យនឹងព្រៃឈើ និងក្រសួងបរិស្ថានចុះកិច្ចព្រមព្រៀង ដើម្បីប្តេជ្ញាចិត្តក្នុងកិច្ចការពារធនធានធម្មជាតិក្នុងតំបន់ទេសភាពខ្ពង់រាបភាគខាងកើត

**សមាជិកតំបន់ការពារធម្មជាតិប្រមាណជា ១២.៨០៤ នាក់ ទទួលបានសិទ្ធិស្របច្បាប់ពេញលេញក្នុងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាពបន្ទាប់ពីចុះហត្ថលេខាលើកិច្ចព្រមព្រៀងតំបន់ការពារធម្មជាតិជាមួយក្រសួងបរិស្ថាន។**

ខេត្តមណ្ឌលគិរី ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩៖ តំណាងសហគមន៍មកពីសហគមន៍តំបន់ការពារធម្មជាតិចំនួន ១២ ក្នុងដែនជម្រកសត្វព្រៃភ្នំព្រេច ស្រែពក និងកែវសីមា ក្នុងខេត្តមណ្ឌលគិរី បានចុះហត្ថលេខាកិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិជាមួយនិងអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាននៃក្រសួងបរិស្ថាន។ ពិធីចុះកិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិដែលប្រារព្ធធ្វើឡើងនៅភូមិអញ្ជរ ឃុំសុខសាន្ត ស្រុកកោះញែក ខេត្តមណ្ឌលគិរី នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ នេះ អាចប្រព្រឹត្តទៅបានក្រោយពីមានកិច្ចខិតខំប្រឹងប្រែងរួមគ្នារវាងក្រសួងបរិស្ថាន មន្ទីរបរិស្ថានខេត្តមណ្ឌលគិរី អាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូពាក់ព័ន្ធដោយមានការគាំទ្រពីអង្គការ WWF-កម្ពុជាចាប់ពីឆ្នាំ ២០០៦ មកម្ល៉េះ ដើម្បីប្រកាសទទួលស្គាល់សហគមន៍តំបន់ការពារធម្មជាតិ (CPA) ស្របបច្បាប់ដោយអនុលោមតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិរបស់ព្រះរាជាណាចក្រកម្ពុជា ។

សហគមន៍តំបន់ការពារធម្មជាតិដែលទើបប្រកាសទទួលស្គាល់នេះ មានចំនួន១២សហគមន៍ គ្របដណ្តប់លើផ្ទៃដីព្រៃឈើទំហំ ៤៥.១៣៩ ហិកតា ហើយមានសមាជិកសហគមន៍ប្រមាណជា ១២.៨០៤ នាក់ (៤៦% ជាស្ត្រី) នឹងទទួលបានសិទ្ធិស្របច្បាប់ពេញលេញ ភាពជាម្ចាស់ និងទំនួលខុសត្រូវ ក្នុងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាពនៅក្នុងសហគមន៍របស់ខ្លួន។ ពួកគាត់ អាចរៀបចំបង្កើត និងអនុវត្តផែនការសម្រាប់ការគ្រប់គ្រងធនធានធម្មជាតិនៅក្នុងតំបន់សហគមន៍ និងអាចប្រើប្រាស់ធនធានទាំងនេះប្រកបដោយចីរភាព ដូចជាការទាញផលអនុផលព្រៃឈើ (NTFPs) និងអេកូទេសចរណ៍ ដោយផ្អែកលើ

ច្បាប់តំបន់ការពារ។ ការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ មានការចូលរួមចំណែកគាំទ្រដោយសហភាពអឺរ៉ុប (EU) ទីភ្នាក់ងារសហរដ្ឋអាមេរិក USAID ជំនួយប្រទេសអាល្លឺម៉ង់ BMZ GEF និងកម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិ UN Environment តាមរយៈគម្រោងកាំប៉ាស់ (CAMPAS)។

ក្រៅពីការទាញផលអនុផលព្រៃឈើសម្រាប់ប្រើប្រាស់ក្នុងសហគមន៍ និងការចិញ្ចឹមជីវិត សមាជិកសហគមន៍តំបន់ការពារធម្មជាតិ ក៏បានសហការជាមួយមន្ត្រីអនុវត្តច្បាប់របស់ក្រសួងបរិស្ថាននិងអាជ្ញាធរដែនដី ដើម្បីដើរល្បាតព្រៃ ទប់ស្កាត់បទល្មើសព្រៃឈើ និងប្រមូលអន្ទាក់សត្វព្រៃនៅក្នុងតំបន់របស់សហគមន៍តំបន់ការពាររបស់ពួកគាត់ផងដែរ។ លោក ប្រោយ ខ្មើក ប្រធានសហគមន៍តំបន់ការពារត្រពាំងក្មើមបាននិយាយថា៖ "ការដើរល្បាត មានសារសំខាន់សម្រាប់ខ្ញុំណាស់ព្រោះធនធានព្រៃឈើជាឆ្នាំងបាយរបស់ប្រជាជនសហគមន៍ទាំងអស់ ទាំងជំនាន់បច្ចុប្បន្ននិងជំនាន់ក្រោយៗទៀត។" បច្ចុប្បន្ននេះ មានសមាជិកក្រុមល្បាតសហគមន៍សរុបចំនួន ៥៧៧ នាក់ កំពុងចូលរួមយ៉ាងសកម្មក្នុងការការពារព្រៃឈើ ក្នុងដែនជម្រកសត្វព្រៃភ្នំព្រេច និងស្រែពក។

អង្គការ WWF-កម្ពុជា បានគាំទ្រ និងសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងបរិស្ថាន មន្ទីរបរិស្ថានខេត្តមណ្ឌលគិរី និងអង្គការដៃគូនានា ក្នុងការរៀបចំ និងជួយពង្រឹងសហគមន៍តំបន់ការពារធម្មជាតិទាំងនេះ តាមរយៈការជួយអន្តរាគមន៍ទប់ស្កាត់បទល្មើសនានា ជួយសម្របសម្រួលរៀបចំចងក្រងរចនាសម្ព័ន្ធលក្ខន្តិកៈសហគមន៍ ជួយវាយតម្លៃលើធនធានដែលមានក្នុងតំបន់ និងកំណត់ព្រំសីមា ជួយរៀបចំផែនការគ្រប់គ្រងតំបន់សហគមន៍ ផ្តល់សម្ភារៈ ឧបករណ៍ចំបាច់សម្រាប់ការគ្រប់គ្រង និងការកែច្នៃផលអនុផលព្រៃឈើ ផ្តល់ការបណ្តុះបណ្តាលសមត្ថភាពលើជំនាញជាច្រើន ដល់សមាជិកសហគមន៍ ផ្តល់ការគាំទ្រហិរញ្ញប្បទានខ្នាតតូចជូនសហគមន៍នីមួយៗ សម្រាប់ការអនុវត្តផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ។

ថ្លែងទៅកាន់អ្នកចូលរួមទាំងអស់ក្នុងពិធីប្រកាសកាលពីព្រឹកមិញ លោក សេង ទៀក នាយកអង្គការ WWF-កម្ពុជា បានមានប្រសាសន៍ថា៖ "គោលបំណងសំខាន់នៃការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ គឺដើម្បីជួយពង្រឹងនិងបង្កើនប្រសិទ្ធិភាពគ្រប់គ្រងធនធានព្រៃឈើ ជីវៈចម្រុះ និងសត្វព្រៃ ក្នុងតំបន់ការពារធម្មជាតិ និងទទួលស្គាល់សិទ្ធិជាម្ចាស់និងតួនាទីស្របច្បាប់លើការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ធនធានរួមរបស់សហគមន៍ប្រកបដោយនិរន្តរភាព និងការទទួលខុសត្រូវខ្ពស់។"

លោកជំទាវ ម៉ុម ថានី រដ្ឋលេខាធិការក្រសួងបរិស្ថាន មានប្រសាសន៍ថា៖ "ក្រសួងបរិស្ថានសូមសម្តែងនូវការគាំទ្រ និងចូលរួមយ៉ាងសកម្មជាមួយស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត នៅក្នុងដំណើរការរៀបចំ និងអនុវត្តការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ សហគមន៍មូលដ្ឋាន គឺជាកម្លាំង

ចលករមួយដែលបានរួមចំណែកយ៉ាងសកម្មក្នុងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព ព្រោះថា សហគមន៍មូលដ្ឋានគឺជាអ្នកដែលរស់នៅក្នុង និងក្បែរតំបន់ការពារធម្មជាតិ ដោយពឹងអាស្រ័យដោយផ្ទាល់លើធនធានធម្មជាតិក្នុងការទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃសម្រាប់រយៈពេលយូរអង្វែង។"

លោក ឈឹម កាន អភិបាលរងនៃគណៈអភិបាលខេត្តមណ្ឌលគិរី បានមានប្រសាសន៍ថា៖ "ខេត្តមណ្ឌលគិរីសម្បូរទៅដោយធនធានព្រៃឈើ និងធនធានជីវចម្រុះដ៏សម្បូរបែប។ វាជាជម្រកសត្វព្រៃសំខាន់ៗដែលជាប្រភេទសត្វរងគ្រោះថ្នាក់ជាសកលជាច្រើនដូចជា សត្វទន្សោង ខ្លារខិន ដំរីអាស៊ី ខ្ទីង រមាំង ក្ងោក និងត្រយងយក្ស។ យើងត្រូវតែពួតដៃគ្នាក្នុងការការពារធនធានធម្មជាតិដ៏មានតម្លៃទាំងអស់នេះ ហើយសហគមន៍ជាបេះដូងនៃកិច្ចសហការរួមគ្នានេះ។"

គួររំលឹកដែរថា រហូតមកដល់បច្ចុប្បន្ន សហគមន៍តំបន់ការពារធម្មជាតិទាំងអស់ក្នុងដែនជម្រកសត្វព្រៃភ្នំព្រេច ស្រែពក និងកែវសីមា សរុបមានចំនួន១៩សហគមន៍ ដែលគ្របដណ្តប់លើផ្ទៃដីព្រៃទំហំ ៦០.៧៩៩ ហិកតា។ សមាជិកសហគមន៍ប្រមាណជា ១៥.០០០ (៥២% ជាស្ត្រី) ដែលមកពីសហគមន៍តំបន់ការពារទាំង ១៩ នោះ បានពឹងអាស្រ័យផលអនុផលព្រៃឈើដោយផ្ទាល់។ បើតាមការវាយតម្លៃត្រួសៗ សហគមន៍តំបន់ការពារធម្មជាតិនីមួយៗ នៃសហគមន៍តំបន់ការពារធម្មជាតិទាំង ១៩ នោះ អាចរកប្រាក់ចំណូលបាន ១៤.៦០០ ដុល្លារសហរដ្ឋអាមេរិក ក្នុងមួយឆ្នាំៗ ពីផលិតផលអនុផលព្រៃឈើ (NTFPs) ដូចជា ការផ្អែបឫស្សី ការយកទឹកឃ្មុំព្រៃ ជ័រទឹក និងជ័រចុង បន្លែព្រៃ ផ្សិត និងផ្លែឈើព្រៃ។

---

ទាញយករូបភាព៖
https://drive.google.com/drive/folders/1nLtTBjvg9DAn57tiLiPpfI5pKFSBRS1V?usp=sharing

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖

លោក ទេព អស្នារិទ្ធ
ប្រធានកិច្ចការសាធារណៈ និងគ្រប់គ្រងព័ត៌មាន នៃអង្គការ WWF-កម្ពុជា
ទូរស័ព្ទលេខ៖ ០១២ ៩៥៧ ៩១៩
អ៊ីម៉ែល៖ asnarith.tep@wwf.org.kh

អំពីអង្គការ WWF-កម្ពុជា៖

អង្គការ WWF ត្រូវបានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ ១៩៩៨ ។ បេសកកម្មរបស់អង្គការ WWF គឺធានាឱ្យមានការចូលរួមគាំទ្រពីមនុស្សគ្រប់រូបដើម្បីធ្វើការអភិរក្សនូវជីវៈចម្រុះដ៏សម្បូរបែបនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អង្គការ WWF-កម្ពុជា នឹងជម្រុញឱ្យមានឱកាសថ្មីៗជាច្រើនដែលផ្តល់ផលប្រយោជន៍ដល់មនុស្ស និងធ្វើឱ្យប្រសើរឡើងនូវកម្រិតជីវភាពរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ព្រមទាំងចូលរួមកាត់បន្ថយភាពក្រីក្រ តាមរយៈការលើកទឹកចិត្តឱ្យមានការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព។

សម្រាប់ព័ត៌មានលំអិតសូមចូលទៅកាន់គេហទំព័ររបស់អង្គការ WWF-កម្ពុជា wwf.org.kh